# សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់
# ក្នុងពិធីសម្ពោធអាគារទីស្តីការ ក្រសួងពាណិជ្ជកម្មថ្មី

ដោយអាគារទីស្តីការក្រសួងពាណិជ្ជកម្មចាស់ នៅតាមបណ្តោយមហាវិថីព្រះនរោត្តម ស្ថិតក្នុងខណ្ឌដូនពេញ រាជធានីភ្នំពេញ មានលក្ខណៈចង្អៀត មិនសមស្រប និងចំនួនមន្ត្រីរាជការ ជាសំណង់ចាស់ សាងសង់ក្នុងទស្សវត្សទី៦០ មានលក្ខណៈមិនរឹងមាំ ជួបការលំបាក ក្នុងការចតយានយន្តមន្ត្រីរាជការ ក៏ដូចជា ភ្ញៀវជាតិ និងអន្តរជាតិ ដែលមានទំនាក់ទំនងជាមួយក្រសួង ក្រសួងពាណិជ្ជកម្ម បានធ្វើសំណើស្នើសុំដោះដូរទីតាំងក្រសួងពាណិជ្ជកម្ម ដែលរួមបញ្ចូលសហគ្រាសជួសជុលរថយន្តធុនតូច TOYOTA ជាថ្នូរជាមួយនិងទីតាំង និងសំណង់ក្រសួងពាណិជ្ជកម្មថ្មី ដែលមានទីតាំងស្ថិតនៅ ក្នុងភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌ សែនសុខ រាជធានីភ្នំពេញ ត្រូវបានប្រារព្ធពិធីសម្ពោធ នៅព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១០ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ។ សមាសភាពចូលរួមនាឱកាសនោះ រួមមាន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ជាសមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល មន្ត្រីរាជការក្រោមឱវាទក្រសួងពាណិជ្ជកម្ម និងតំណាងស្ថានទូតនានាប្រចាំកម្ពុជា យ៉ាងច្រើនកុះករ ។ ដោយឡែក ឯកឧត្តម លោកជំទាវ ជាអតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងក្រុមគ្រួសារអតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលទទួលមរណភាពទៅហើយ ក៏មានវត្តមានចូលរួមនាឱកាសនោះផងដែរ ។

ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមានប្រសាសន៍សំដែង នូវការស្វាគមន៍រីករាយ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានឆ្លៀតឱកាសដ៏មមាញឹក អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នូវអគារទីស្តីការក្រសួងពាណិជ្ជកម្ម ដែលទើបសាងសង់ថ្មីនេះ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានរៀបរាប់ពីប្រវត្តិសង្ខេបនៃការវិវត្តន៍រីកចំរើនរបស់ក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃកកើតដំបូង រហូតមកដល់បច្ចុប្បន្ន ជាពិសេស គឺបន្ទាប់ពីមាតុភូមិកម្ពុជាបានរំដោះថ្ងៃ ៧មករា ឆ្នាំ ១៩៧៩ ។ ឯកឧត្តមបានបញ្ជាក់ថា: ក្រោយថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ វិស័យពាណិជ្ជកម្មកម្ពុជាបានចាប់ផ្តើមពីស្ថានភាពប្រទេសមួយដែលចាប់ផ្តើមពី ចំណុចសូន្យនិងអភិវឌ្ឍន៍ឡើងវិញបន្ទាប់ពីការចាប់ផ្តើម គ្មានទីផ្សារ គ្មានរូបិយបណ្ណ័ជាតិ ទីក្រុងគ្មានមនុស្សរស់នៅ ហេដ្ឋារចនាសម្ពន្ធ័ទាំងមូលត្រូវបំផ្លិចបំផ្លាញដល់ឫសគល់។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជានៃសាធារណរដ្ឋប្រជាមានិតុកម្ពុជា ដែលត្រូវបានបង្កើតឡើងនាថ្ងៃទី ០៨ ខែមករា ឆ្នាំ ១៩៧៩ ដែលជាតំណាងស្របច្បាប់តែមួយគត់របស់ប្រទេស និង ប្រជាជនកម្ពុជា បានចាប់ផ្តើមស្តារប្រទេសឡើងវិញពីចំណុចសូន្យ ហើយត្រូវគេហ៊ុំព័ទ្ធខាងសេដ្ឋកិច្ច យ៉ាងអយុត្តិធមិថែមទៀត។ ក្រុមប្រឹក្សា ប្រជាជនបដិវត្តន៍កម្ពុជា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបង្កើតក្រសួង ស្ថាប័នមួយចំនួន ដែលក្នុងពេល នោះពុំទាន់មានក្រសួងពាណិជ្ជកម្មនៅឡើយទេ។ នៅជំនាន់នោះ ការគ្រប់គ្រងវិស័យពាណិជ្ជកម្មស្ថិតនៅក្រោមសមត្ថកិច្ចនៃ **ក្រសួងសេដ្ឋកិច្ច និងជីវភាព** ដែលមាន ឯកឧត្តម **ម៉ុក សុគន្ធ**

ទទួលជារដ្ឋមន្ត្រី នៅថ្ងៃទី ៨ មករា ១៩៧៩។ ក្រោយពេលដែលឯកឧត្តម **ម៉ុក សុគន្ធ** ទទួលមរណៈភាព ក្រសួងនេះត្រូវបានដឹកនាំដោយ ឯកឧត្តម **រស់ សម័យ** ចាប់ពីថ្ងៃទី ១៥ ឧសភា ១៩៧៩ ដល់ថ្ងៃទី ២៤ តុលា ១៩៧៩។ បន្ទាប់មកទៀត នៅថ្ងៃទី ២៤ តុលា ១៩៧៩ **ក្រសួងពាណិជ្ជកម្ម** ក៏ត្រូវបានបង្កើតឡើង ដោយមាន ឯកឧត្តម **តាំង សារឹម** ជារដ្ឋមន្ត្រី ។ **ក្រសួងពាណិជ្ជកម្ម** មានថ្នាក់ដឹកនាំបន្តបន្ទាប់ដូចជា ឯកឧត្តម **ចាន់ ភិន** , លោកជំទាវ **ឃូ ណារុន** , វិលមក ឯកឧត្តម **តាំង សារឹម** ម្តងទៀត, ឯកឧត្តម **ញឹម វណ្ណដា** , ឯកឧត្តម **វ៉ា ឃួត** និង រូបឯកឧត្តមផ្ទាល់រហូតដល់ពេលបច្ចុប្បន្ននេះ ។

ចំពោះដំណើរការនៃការសាងសង់អគារទីស្តីការក្រសួងពាណិជ្ជកម្មថ្មី ឯកឧត្តមទេរដ្ឋមន្ត្រីបានបញ្ជាក់ថាៈក្រសួងពាណិជ្ជកម្មបានធ្វើសំណើស្នើសុំដោះដូរទីតាំងក្រសួងពាណិជ្ជកម្ម ដែលរួមបញ្ចូលសហគ្រាសជួសជុលរថយន្តធុនតូច TOYOTA ជាថ្នូរជាមួយនឹងទីតាំង និងសំណង់ក្រសួងពាណិជ្ជកម្មថ្មីនេះ តាមលិខិត លេខ ៣១៥ MOC/M ២០០៥ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ ហើយដែលបានយល់ព្រម ពីរាជរដ្ឋាភិបាលតាមលិខិតលេខ ២៧៧ សជណ ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ ៤០៥៩ សហវ ទរ ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលិខិតលេខ៤៨០៤ សហវ.ទរ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឱ្យក្រុមហ៊ុន អ៊ែតរូតជាអ្នកសាងសង់ ដែលមានតម្លៃដោះដូរចំនួន **៩.៤៥០.៤៤៤.៦៩$** (ប្រាំលានបួនរយហាសិបពាន់ បួនរយសែសិបបួន ក្បៀស ហុកសិបប្រាំបួន ដុល្លារអាមេរិក)។ ដោយឡែក ទីស្តីការក្រសួងពាណិជ្ជកម្ម ថ្មីនេះមានតម្លៃសរុប **៩.៣១៣.៥១៣.៦៤$** (ប្រាំលានបីរយដប់បីពាន់ ប្រាំរយដប់បី ក្បៀសហុកសិបបួន ដុល្លារអាមេរិក) ដោយក្នុងនោះមានតម្លៃដី១.៩១១.០០០,០០$ (មួយលានប្រាំបួនរយដប់មួយពាន់ ដុល្លារអាមេរិក) តម្លៃសំណង់អាគារ **២.៤៣៧.៧៣១.៤២$** (ពីរលាន បួនរយសាមសិប ប្រាំពីរពាន់ ប្រាំពីររយសាមសិបមួយ ក្បៀសសែសិបពីរ ដុល្លាអាមេរិក) និងតំលៃបំពាក់ដោយគ្រឿងសង្ហារឹម ១.០៦៤.៧៨២,៥៨$ (មួយលាន សូន្យរយហុកសិបបួនពាន់ ប្រាំពីររយ ប៉ែតសិបពីរ ក្បៀស ហាសិបប្រាំបីដុល្លាអាមេរិក)។ សរុបចាប់ពីដំណើរការសាងសង់ រហូតដល់ស្ថាបនារួចរាល់ជាស្ថាពរ នាថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០៩ គឺប្រើប្រាស់ពេលវេលាអស់ប្រមាណ ២ឆ្នាំ ៥ ខែ ។

អាគារទីស្តីការក្រសួងពាណិជ្ជកម្មថ្មីនេះ មានអាគារធំ២ចំនួន អគារមុខមានកំពស់ ៤ ជាន់ និងអាគារក្រោយមានកំពស់ ៦ជាន់មានផ្ទៃក្រឡាបាតសរុប ២.៤៦៩ ម៉ែតការ៉េ ដោយសាងសង់លើផ្ទៃដីទំហំ ១៣.៦៥០ ម៉ែតការ៉េ ស្មើនិងប្រមាណ ១៨,០៩ នៃផ្ទៃដីសរុប និងមានផ្ទៃក្រឡាបាត ប្រើប្រាស់ ជាការិយាល័យធ្វើការសរុប **១២.១៩៦,៨** (មួយម៉ឺនពីរពាន់មួយរយកៅសិបប្រាំមួយ ក្បៀសប្រាំបីម៉ែត្រក្រឡា) អាគារនេះមាន លក្ខណៈច្របាច់ចូលគ្នារវាងរចនាបទបែបបុរាណនិងរចនាបទបែបសម័យទំនើបបច្ចុប្បន្ន។ ដំបូលអគារយកលំនាំ តាមដំបូលផ្ទះ បុរាណខ្មែរ ដែលមាន រាងធំ តូច ខ្ពស់ទាបតំណាងឱ្យឋានានុក្រម និងការទំនាក់ទំនង។ ផ្នែករង្វង់នៅប៉ែកខាងមុខ និងខាងកើតនៃអាគារ ត្រូវបានបំពាក់ដោយរូបសញ្ញា និងឈ្មោះក្រសួងពាណិជ្ជកម្ម ដែលជាវិស័យអាទិភាពមួយ ក្នុងចំណោមវិស័យអាទិភាពទាំង១០ របស់រាជរដ្ឋាភិបាល បានរួមចំណែកបង្កើតការងារជូនប្រជាពលរដ្ឋដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ។

អាគារទីស្តីការត្រូវបានសាងសង់ឡើងដោយគោរពតាមបទដ្ឋាននៃការសាងសង់អាគារការិយាល័យ និងការកែច្នៃប្រឌិត យកបរិស្ថានធម្មជាតិជីវិញមកប្រើប្រាស់ដើម្បីផ្តល់ឱ្យអគារនូវប្រព័ន្ធខ្យល់ ពន្លឺ និងការពារកំដៅ ដែលទាំងនេះជាគោលការណ៍នៃ ការសន្សំសំចៃថាមពលអគ្គិសនី និងផ្តល់មកវិញនូវផាសុខភាពបែបធម្មជាតិ។

អាគារទីស្តីការនេះ មានជណ្តើរយន្តចំនួន ៣ គ្រឿង, មានសាលប្រជុំដែលអាចផ្ទុកចំណុះបានពី ៣០នាក់-៤០នាក់ ចំនួន ២ បន្ទប់, ចំណុះពី១០០នាក់-១២០នាក់ ចំនួន ១ បន្ទប់, ចំណុះពី ៣០០នាក់-៣៥០នាក់ ចំនួន ១បន្ទប់, សាលសិក្សា ចំនួន ៣ បន្ទប់ និងបន្ទប់ប្រជុំតូចៗចំនួន ៣ បន្ទប់ទៀតមានបណ្ណាល័យ១ និងមានអាហារដ្ឋានមួយមានបន្ទប់សំរាប់ធ្វើ (Video Conference) បន្ទប់ដាក់ទូរបញ្ជូអ៊ិនធើណែត (Server Internet) ក្នុងរង្វង់ទិស្តីការក្រសួង អាចប្រើប្រាស់អ៊ិនធើណេតគ្រប់ទីកន្លែងតាមរយៈប្រព័ន្ធ (Wireless)។ អាគារទាំងមូលមានបំពាក់ម៉ាស៊ីនត្រជាក់គ្រប់ប្រភេទចំនួន ១២២គ្រឿង, កង្ហាចំនួន៣៦០គ្រឿង។ បន្ទប់ការិយាល័យធ្វើការនីមួយៗបានបំពាក់ទៅដោយគ្រឿងសង្ហារឹមការិយាល័យធ្វើការសមរម្យ និងមានទំនាក់ទំនងពីមួយ ទៅមួយយ៉ាងល្អ (Network System) និងប្រព័ន្ធព័ត៌មាន (Internet) សម្ភារៈ ឧបករណ៍តាមប្រពន្ធ័ព័ត៌មានវិទ្យាទំនើប ក្រៅពីផ្ទៃដីសាងសង់អាគារ ដីដែលនៅសេសសល់ បានរៀបចំឱ្យមានចំណត រថយន្ត-ម៉ូតូធំទូលាយ។

បច្ចុប្បន្នបុគ្គលិក មន្ត្រីរាជការក្រសួងពាណិជ្ជកម្ម សរុបមានចំនួន **១.៦៤៧** នាក់ ក្នុងនោះ នៅថ្នាក់កណ្តាលមានចំនួន **១.១១៤** នាក់ និងនៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តទាំង២៤ ចំនួន **៥៣៣** នាក់។ រចនាសម្ពន្ធ័បំរើការងារមានអគ្គនាយក ដ្ឋានចំនួន៤គឺៈ អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស, អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ និង អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) និងមាននាយកដ្ឋានចំណុះ ចំនួន ១៩ (រាប់ទាំង អគ្គាធិការដ្ឋាន ) និងក្រុមហ៊ុនប្រ៊្កីនត្រេដ ជាសហគ្រាសសាធារណៈ ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងន័យមួយដើម្បីរំលឹកដល់គុណូបក្ការៈដ៏ថ្លៃថ្លា របស់វីរៈជនដ៏ឆ្នើម ០១ រូប ក្នុងសតវត្សទី១៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់ជាអំណោយដល់ក្រសួងពាណិជ្ជកម្ម នូវរូបសំណាក **ព្រះស្រីជេដ្ឋាព្រះស្តេចកន** ដែលយើងខ្ញុំទាំងអស់គ្នា បានយកមកដំកល់ជាប់នឹងដងទង់ជាតិ នៅខាងមុខ វេទិកានេះ ដើម្បីទុកជាទីគោរពសក្ការៈហើយត្រូវបានមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់របស់ក្រសួងពាណិជ្ជកម្មប្រារព្ធពិធីបួងសួង សុំពរជ័យបវរ សួស្តី សេចក្តីសុខកាលពី ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១០ កន្លងមកនេះ។ គំរូ **ព្រះស្រីជេដ្ឋា ព្រះស្តេចកន** ក៏ដូចគំរូ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** គឺជាគំរូវីរភាពនៃកុលបុត្រខ្មែរ កើតចេញ ពីត្រកូលកសិករ ខិតខំពុះពារគ្រប់ឧបសគ្គ រហូតបានឡើងដឹកនាំវាសនាប្រទេសជាតិ ឈានទៅរកការឯកភាពទឹកដី និងភាពសំបូរ រុងរឿងជូនប្រជានុរាស្ត្រ។ យើងខ្ញុំទាំងអស់គ្នា ជាមន្ត្រីរាជការក្នុងក្រសួងពាណិជ្ជកម្ម សូមយកគំរូវីរភាពនេះ ដាក់ជាប់ក្នុងចិត្ត ព្យាយាមបំពេញការងារដែលរាជរដ្ឋាភិបាល និងប្រជាជនប្រគល់ជូន ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។ ជូសមុខឱ្យមន្ត្រី រាជការក្រសួងពាណិជ្ជកម្ម យើងខ្ញុំ

ទាំងអស់គ្នាសូមគាំទ្របេក្ខភាព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជា **នាយករដ្ឋមន្ត្រី** សម្រាប់អាណត្តិក្រោយៗទៀត ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានធ្វើការគូសបញ្ជាក់ថា: វិស័យពាណិជ្ជកម្មកម្ពុជាគឺជាវិស័យ មួយដែលមានលក្ខណៈជាប្រពន្ធ័ និងជាវិស័យអទិភាព មួយក្នុងចំណោមវិស័យ អទិភាពសេដ្ឋកិច្ចសំខាន់ៗទាំង ១០ ក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលអាណត្តិទី៤នេះ ។

ដើម្បីរួមចំណែកអនុវត្ត **ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** និងជាពិសេសការបន្តជំរុញការអនុវត្ត **យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី២** របស់រាជរដ្ឋាភិបាល ដើម្បី ***កំណើនការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួងពាណិជ្ជកម្ម និងបន្តអនុវត្តន៏ ឱ្យបានជោគជ័យនូវនយោបាយនេះ ដោយផ្តោតលើចំណុចសំខាន់ៗ ដូចខាងក្រោម :

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋ បាលសាធារណៈ
- បន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់និងសហគមន៍អន្តរជាតិបន្តបើកច្រកឱ្យផលិតផលកម្ពុជាអា ឈានចូលដោយ គ្មានរបាំង និងឧបសគ្គនានា ទៅកាន់ទីផ្សារដ៏ធំធេង នៅក្នុងតំបន់ និងក្នុងពិភពលោក
- គ្រប់គ្រងថ្លៃទំនិញប្រើប្រាស់ជាមូលដ្ឋានសំខាន់ៗ ដូចជាម្ហូបអាហារ និងប្រេងឥន្ទនៈ
- ការធ្វើពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា
- ធ្វើឱ្យតម្លៃនៃការធ្វើធុរកិច្ចថយចុះ និងពង្រីកទីផ្សារ កាត់បន្ថយចំណាយដឹកជញ្ជូន
- ការដាក់ឱ្យអនុវត្តនូវប្រព័ន្ធ រដ្ឋបាលតែមួយ និង សេវាច្រកចេញចូលតែមួយ
- បន្តខិតខំប្រឹងប្រែងដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ
- បន្តពង្រឹងក្របខ័ណ្ឌគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជនរួមមានបទបញ្ញត្តិច្បាប់ និង នីតិវិធីរដ្ឋបាល
- បន្តជំរុញកិច្ចសំរួលពាណិជ្ជកម្ម
- បន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ រោងចក្រល្អប្រសើរ
- បង្កើនការគ្រប់គ្រង រៀបចំយុទ្ធសាស្រ្ត វិភាគ និងអនុវត្តនគោលនយោបាយពាណិជ្ជកម្មក្នុងស្រុក និងក្រៅប្រទេសអភិវឌ្ឍន៏ទីផ្សារចាស់ និងស្វែងរកទីផ្សារថ្មីៗ ។

មានប្រសាសន៏សំណេះសំណាល នាឱកាសនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៏ សំដែងនូវទឹកចិត្តរីករាយនិងមោទនៈភាពចំពោះពិធីសម្ពោធអគារទីស្តីការក្រសួងពាណិជ្ជកម្មថ្មី ស្របតាមការវិវឌ្ឍន៏នៃវិស័យពាណិជ្ជកម្មកម្ពុជា នាពេលបច្ចុប្បន្ន ព្រមទាំងវាយតំលៃខ្ពស់ចំពោះសមិទ្ធផល ដ៏ធំធេង ដែលក្រសួងពាណិជ្ជកម្មសំរេចបាន ជាបន្តបន្ទាប់ ដោយឆ្លងកាត់នូវប្រវត្តិ និងការវិវឌ្ឍន៏ជាដំណាក់កាល តាមរបបសេដ្ឋកិច្ចនីមួយៗ តាំងពីរបបសេដ្ឋកិច្ច មានផែនការ ដែលពេលនោះក្រសួងពាណិជ្ជកម្មមាន ឈ្មោះដំបូងថា: ក្រសួងសេដ្ឋកិច្ច និងជីវភាព ដែលបានប្រតិបត្តិការការងាររបស់ខ្លួនយ៉ាងសកម្ម និងលំបាកបំផុតក្នុងស្ថានភាពដែលវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច របស់កម្ពុជាត្រូវបានគេហ៊ុំព័ន្ធយ៉ាងអយុត្តិធម៌ ។ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**

បានរំលឹកពីប្រវត្តិ នៃការកកើតក្រសួងពាណិជ្ជកម្ម ក្រោយថ្ងៃរំដោះ ០៧ មករា ឆ្នាំ១៩៧៩ និងស្នាដៃរបស់អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ន ដែលបានដើរតួយ៉ាងសំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍន៍ខឿនសេដ្ឋកិច្ចជាតិ លើកកំពស់ជីវភាពប្រជាពលរដ្ឋ និងការកាត់បន្ថយភាពក្រីក្រ ។

ក្នុងអតីតសាធារណៈរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា មន្ត្រីរាជការបុគ្គលិកកម្មករក្រសួង ពាណិជ្ជកម្ម បានអនុវត្តនូវតួនាទីភារកិច្ចរបស់ខ្លួន យ៉ាងសកម្ម ហើយក្នុងពេលនោះមានមន្ត្រីបុគ្គលិក កម្មករ យើងមួយចំនួនត្រូវបានពលី និងរបួសពិការក្នុងបេសកកម្មជាប្រវត្តិសាស្ត្រ ក្នុងបុព្វហេតុការពារ និងកសាងមាតុភូមិទប់ស្កាត់នូវការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ប៉ុលពត ជាមួយនេះដែរ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃក្រសួងបានរួមចំណែកសង្គ្រោះប្រជាជនឱ្យរួចផុតពីភាពអត់ឃ្លាន និងបាន ចូលរួមយ៉ាងសកម្មក្នុងការប្រមូលទិញស្បៀង បែងចែក ផ្គត់ផ្គង់សម្ភារៈជូនកងកម្លាំងប្រដាប់អាវុធ និង ប្រជាជនទូទាំងប្រទេស ធ្វើឱ្យជីវភាពប្រជាជនមានស្ថិរភាពជាបណ្តើរៗ។ក្រសួងនេះធ្លាប់មានបទពិសោធន៍អនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្ថានភាពដែលប្រទេសមានសន្តិភាព ផងនិងសង្គ្រាមផង ពិសេសក្នុងស្ថានភាពដែលវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច ត្រូវបានគេហ៊ុំព័ទ្ធយ៉ាង អយុត្តិធម៌ ។

ក្នុងដំណាក់កាលនៃការកែទម្រង់សេដ្ឋកិច្ច ដែលពេលនោះជាកាលៈទេសៈដ៏គ្រោះថ្នាក់បំផុត រូបខ្ញុំជាអ្នកដឹកនាំបញ្ជាផ្ទាល់ ក៏ក្រសួងនេះធ្លាប់បានបំពេញតួនាទីភារកិច្ច ធ្វើឱ្យកំណែទម្រង់សេដ្ឋកិច្ចបាន ជោគជ័យជាបន្តបន្ទាប់រហូតដល់សព្វថ្ងៃនេះ។

ក្នុងដំណាក់កាលនៃរាជរដ្ឋាភិបាលបណ្តោះអាសន្ន រាជរដ្ឋាភិបាលនីតិកាលទី១នៃរដ្ឋសភា រាជរដ្ឋាភិបាលនីតិកាលទី២នៃរដ្ឋសភា ពិសេសក្នុងដំណាក់កាលដែលសម្តេចទទួលបន្ទុកជានាយករដ្ឋមន្ត្រី ក្រសួងនេះ ស្ថិតក្រោមការចង្អុលណែនាំរបស់សម្តេចផ្ទាល់ សម្តេច បានរួមចំណែកយ៉ាងសំខាន់ក្នុងបុព្វហេតុកសាង ប្រទេស ដែលក្នុងនោះ យើងអាចកត់សំគាល់បាននូវជោគជ័យសំខាន់ៗមួយចំនួនដូចខាងក្រោម :

-បានចូលរួមធ្វើឱ្យសម្រេចជោគជ័យក្នុងការធ្វើសមាហរណកម្មព្រះរាជាណាចក្រកម្ពុជា ទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិទាំងមូល ក្នុងនាមជាប្រជាជាតិដែលស្មើភាព ស្មើសិទ្ធិជាមួយគ្រប់ ប្រទេសទាំងអស់ ក្នុងនោះការចូលជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងអង្គការពាណិជ្ជកម្ម ពិភពលោក នាថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤

-ការពារ និងរក្សាបានស្ថេរភាពខាងវិស័យកាត់ដេរនៅកម្ពុជា ហើយដែលកំពុងបន្តរីកចំរើន

-បានកសាងច្បាប់បញ្ញត្តិមួយចំនួន និងបទបញ្ញត្តិផ្សេងៗទៀត ដើម្បីធានាបាននូវភាពស្របគ្នា ជាមួយអង្គការពាណិជ្ជកម្មពិភពលោក

-បានរួមចំណែកយ៉ាងសំខាន់ ក្នុងការរៀបចំឯកសារ ក្នុងតារាងសន្យាបើកច្រកទីផ្សារ ពាណិជ្ជកម្ម សេវាកម្មជម្រុញឱ្យមានសន្ទុស្សន៍ទៅមុខនៃកម្មវិធីកាត់បន្ថយពន្ធគយរួម សម្រាប់តំបន់ ពាណិជ្ជកម្មសេរីអាស៊ាន (CEPT or AFTA) ការលុបបំបាត់របាំងមិនមែនពន្ធគយ ការពង្រឹងគុណ ភាពទំនិញ និងសេវាឱ្យស្របតាមស្តង់ដារបច្ចេកទេស និងអនាម័យ-ភូតគាមអនាម័យ

-បានរួមចំណែកយ៉ាងសកម្ម ក្នុងការស្នើសុំភាពអនុគ្រោះពន្ធគយលើមុខទំនិញជាច្រើនមុខ សម្រាប់ឱ្យកម្ពុជានាំចេញទៅក្រៅប្រទេស ដោយអត្រាពន្ធសូន្យ ឬ អត្រាពន្ធទាបបំផុត ដែលក្នុងនោះ មានប្រទេសជាច្រើន បានផ្តល់ភាព

អនុគ្រោះពន្ធគយដល់កម្ពុជា ជាអាទិ៍ : សហរដ្ឋអាមេរិក ប្រទេស ចិន ប្រទេសជប៉ុន ប្រទេសកូរ៉េ និងបណ្តាប្រទេសមួយចំនួននៅក្នុងសមាគន៍ប្រទេស ប្រជាជាតិ អាស៊ាន

-បានចរចាប្រកបដោយជោគជ័យបើកច្រកទីផ្សារជាមួយប្រទេសជាសមាជិកអង្គការពាណិជ្ជកម្ម ពិភពលោក ពិសេសជាមួយប្រទេសធំៗមួយចំនួនដូចជាៈ សហរដ្ឋអាមេរិក សហភាពអ៊ឺរ៉ុប ប្រទេសចិន កាណាដា អូស្ត្រាលី...។ល។ តាមរយៈការស្នើសុំលុបចោលពន្ធគយ និងដកចេញនូវវិធានការណ៍មិន មែនពន្ធនានា

-រក្សាស្ថិរភាពថ្លៃឱ្យនៅដដែល ឬមានការកើនឡើងបន្តិចបន្តួចចំពោះមុខទំនិញសំខាន់ៗ ពិសេសមុខទំនិញ ម្ហូបអាហារ អតិបរមា ជាមធ្យមមានការកើនឡើងតិចតួចបំផុត បើប្រៀបធៀបនឹង ឆ្នាំមុនៗកន្លងមក

-បានរួមចំណែកធ្វើឱ្យពាណិជ្ជកម្មក្រៅប្រទេសចាប់ពីឆ្នាំ២០០៣មក ដែលមានទឹកប្រាក់ប្រមាណជាង **បីពាន់លានដុល្លាអាមេរិក** រហូតមកដល់បំណាច់ឆ្នាំ២០០៩កន្លងមកនេះ ពាណិជ្ជកម្មក្រៅប្រទេស មានទឹកប្រាក់ប្រហែល ជាង **មួយម៉ឺនលានដុល្លាអាមេរិក**។

ឆ្លៀតឱកាសនោះ សម្តេចបានផ្តល់អនុសាសន៍មួយចំនួន ដើម្បីឱ្យវិស័យពាណិជ្ជកម្ម សំរេចបាន ជោគជ័យថ្មីៗថែមទៀត រួមមានៈ **១**-ការបង្កើនសមត្ថភាពផ្គត់ផ្គង់ សមត្ថភាពនាំចេញ និងការកាត់បន្ថយឱនភាពពាណិជ្ជកម្ម **២**-ការពង្រីកផលិតផលសំរាប់ផលិតផលកម្ពុជា **៣**-ការពង្រឹងការអនុវត្តន៍ច្បាប់កម្មសិទ្ធិបញ្ញា ការផលិត ការចែកចាយ ផលិតផល ក្លែងបន្លំ ផលិផលគ្មាគុណភាព រឺខូចគុណភាព **៤**-ការរក្សាស្ថេរភាពថ្លៃទំនិញចាំបាច់ **៥**-សមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក ។ ទាក់ទងនិងចំនុចនេះ សម្តេចតេជោ បានបញ្ជាក់ថាៈក្រោម តំបន់ពាណិជ្ជកម្មសេរីអាស៊ានសម្រាប់ប្រព័ន្ធអនុគ្រោះពន្ធរួម (Common Effective Preferential Tarrif for ASEAN Free Trade Area –CEPT/ AFTA ) កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ASEAN Trade in Goods Agreement- ATIGA) វិធាន នេះបានចូលជាធរមាន និងចាប់ផ្តើមអនុវត្តពី ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១០។ កិច្ចព្រមព្រៀង ស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋជាសមាជិកសមាគមន៍ប្រជាជាតិ អាស៊ីអាគ្នេយ៍ និងជប៉ុន ត្រូវបានចូលជាធរមានកាលពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ អត្ថប្រយោជន៍ដែល នឹងទទួលបានពីកិច្ចព្រមព្រៀងនេះ មានចំណុចសំខាន់ៗ ដូចជាការនាំចេញ-នាំចូល នៅក្នុងតំបន់ នឹងទទួលបានអត្រាពន្ធទាប មិនមានរបាំងពាណិជ្ជកម្ម ចំពោះការនាំចេញ-នាំចូល ការប្រកួតប្រជែងមានភាពស្មើគ្នា កម្ពុជាអាចយកវត្ថុធាតុដើមពីបណ្តាប្រទេសសមាជិកអាស៊ាន មកផលិតទំនិញសម្រាប់ការ នាំចេញ។ សម្តេចបានអំពាវនាវដល់គ្រប់ក្រសួងស្ថាប័ន ផ្នែកពាក់ព័ន្ធ ផ្នែកឯកជន និងបងប្អូន ប្រជាពលរដ្ឋយើងទាំងអស់គ្នា ចូលរួមឱ្យបានខ្លាំងក្លាអនុវត្តកិច្ចព្រមព្រៀងទាំងនោះឱ្យបានជោគជ័យ សំដៅជម្រុញការអនុវត្តគោលនយោបាយសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទាំងក្នុងក្របខ័ណ្ឌអនុតំបន់ និង ពិភពលោក សំដៅទទួលបាននូវផលប្រយោជន៍ជាអតិបរមាពីការធ្វើ សមាហរណកម្មនេះ។

មុននិងបញ្ចប់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានផ្តាំផ្ញើដល់មន្ត្រីរាជការក្រសួងពាណិជ្ជកម្មទាំងអស់ថា ឥឡូវនេះ យើងមានអាគារធ្វើការសមរម្យហើយ ចូរខិតខំបំពេញការងារ បង្កើនស្មារតីទទួលខុសត្រូវ និងការប្តេជ្ញាចិត្តខ្ពស់ ក្នុងការងារ។ ទន្ទឹមនឹងនេះ ត្រូវបង្កើនការសន្សំសំចៃលើការចំណាយមួយចំនួនដូចជា ទឹក អគ្គិសនី ប្រេងឥន្ធនៈ ហើយនិងរួមគ្នាថៃរក្សាអនាម័យ បរិស្ថានឱ្យបានល្អ។

ស្ថិតក្នុងឱកាសនោះដែរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញបំពាក់គ្រឿងឥស្សរិយយស **មេដាយ ជាតូបការ** ជូន **ឯកឧត្តម ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានស្នាដៃឆ្នើម ក្នុងការចូលរួមស្តារអភិវឌ្ឍន៍ជាតិ និងកសាងវិស័យពាណិជ្ជកម្មនៅកម្ពុជា ព្រមទាំងបំពាក់ គ្រឿងឥស្សរិយយសដល់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ក្រោមឱវាទក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន ហ្វ្រីគ ត្រេដ ដែលជាសហគ្រាសសាធារណៈចំនួន ២៧រូបទៀត រួមមានៈ **មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេរីវឌ្ឍន៍ ចំនួន ០១ រូប , ថ្នាក់ ធិបឌិន្ទ ចំនួន ០៤ រូប , ថ្នាក់សេនា ចំនួន ០៥ រូប, ថ្នាក់អស្សឫទ្ធិ ចំនួន ០៣ រូប , មេដាយសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ចំនួន ០១ រូប , មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ចំនួន ០១ រូប , មេដាយសុវត្ថារា ថ្នាក់ មហាសេនា ចំនួន ០៧ រូប និង មេដាយសុវត្ថារា ថ្នាក់ សេនា ចំនួន ០៥ រូប ។**

បន្ទាប់មក **សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងគណៈអធិបតីទាំង បានអញ្ជើញ ទស្សនាបរិវេណ ខាងក្នុងនៃទីស្តីការក្រសួងពាណិជ្ជកម្មថ្មី រួមមានអគារសាលប្រជុំ អគារបណ្ណាល័យ និងបន្ទប់ Video Conferance ។